**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**អគ្គនាយកដ្ឋានឃោធសេវា**

**នាយកដ្ឋានព័ត៌មាន**

លេខៈ ២៣៤/ន.ព/២០១៥

# សេចក្ដីជូនដំណឹង

តបតាមការអញ្ជើញរបស់ រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម គណៈប្រតិភូ ជាន់ខ្ពស់ក្រសួងការពារជាតិ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញ ដល់ចំណតអាកាសយានដ្ឋានអន្តរជាតិ ទីក្រុងហាណូយ នៅវេលាម៉ោង២១:០០នាទី ក្នុងដំណើរទៅបំពេញទស្សនកិច្ចផ្លូវការ រយៈពេលបីថ្ងៃ ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

ក្នុងដំណើរ ទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋ សង្គមនិយមវៀតណាម ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** គ្រោងនឹងជួបប្រជុំទ្វេភាគី និងចុះហត្ថលេខាជាមួយ សមភាគីវៀតណាម លើផែនការកិច្ចសហប្រតិបត្តិការ ឆ្នាំ២០១៦ រវាងក្រសួងការពារជាតិ នៃប្រទេសទាំងពីរ ។

បន្ទាប់មក ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** ព្រមទាំងគណៈប្រតិភូ នឹងទៅទស្សនកិច្ច កងវរសេនាតូច រថពាសដែក៤៧ បញ្ជាការដ្ឋាន រដ្ឋធានីហាណូយ ព្រមទាំងអញ្ជើញទៅសួរសុខទុក្ខ សិក្ខាកាមកងយោធពលខេមរភូមិន្ទ ដែលកំពុងសិក្សា នៅសាធារណរដ្ឋសង្គមនិយមវៀតណាមផងដែរ ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៥